ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៤២៦ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៤ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពសមាជិករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៥/៨០៧ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការតែងតាំងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៦/៣១៥ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីការតែងតាំងអភិបាលនៃគណៈអភិបាលខេត្តកំពត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៦៧១ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៤ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ១០៦សសរ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។


www.pheakdeylaw.com

## សម្រេច

**ប្រការ ១._**

កែសម្រួលសមាសភាពគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដែលត្រូវបានតែងតាំងដោយសេចក្តីសម្រេចលេខ១០៦សសរ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា(គ.អ.ឆ.ក.) ដូចតទៅ÷

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានកិត្តិយស**

| | | |
|---|---|---|
| ១-ឯកឧត្តម **ជា សុផារ៉ា** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២-ឯកឧត្តម **សាយ សំអាល់** | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | អនុប្រធាន |
| ៣-ឯកឧត្តម **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤-ឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥-ឯកឧត្តម **ព្រុំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៦-ឯកឧត្តម **វ៉ុល វ៉ាន់សារ៉ាត** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៧-ឯកឧត្តម **ចី ណាយី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៨-ឯកឧត្តម **យុទ្ធ ភូថង** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩-ឯកឧត្តម **តោគ សុវណ្ណារិទ្ធ** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ១០-ឯកឧត្តម **ហូ វិចិត្រ** | រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | សមាជិក |
| ១១-ឯកឧត្តម **តន់ វ៉ាន់ថារ៉ា** | រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ១២-ឯកឧត្តម **លឹម ស៊ីដេនីន** | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១៣-ឯកឧត្តម **ហ៊ូ តាំងអេង** | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១៤-ឯកឧត្តម **តែ គុយស៊ាង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១៥-ឯកឧត្តម **សុខ ចិន្តាសោភា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៦-ឯកឧត្តម **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ១៧-ឯកឧត្តម **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៨-ឯកឧត្តម **យន្ត មីន** | អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ | សមាជិក |
| ១៩-ឯកឧត្តម **ចាន់ ចេស្តា** | អភិបាលនៃគណៈអភិបាលខេត្តកំពត | សមាជិក |
| ២០-ឯកឧត្តម **កែន សត្ថា** | អភិបាលនៃគណៈអភិបាលខេត្តកែប | សមាជិក |
| ២១-ឯកឧត្តម **ម៉ុន សើត** | អភិបាលនៃគណៈអភិបាលខេត្តកោះកុង | សមាជិក |
| ២២-ឯកឧត្តម **ឃុន ឫទ្ធិ** | តំណាងគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ | សមាជិក |
| ២៣-លោក **សុទ្ធ ធី** | តំណាងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | សមាជិក |
| ២៤-ឯកឧត្តម **វ៉ាន់ មុនីនាថ** | តំណាងអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងបរិស្ថាន | សមាជិក |
| ២៥-ឯកឧត្តម **ឆាយ ឫទ្ធិសែន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២៦-ឯកឧត្តម **ម៉ែន សុផល** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក. | សមាជិក។ |


www.pheakdeylaw.com

**ប្រការ ២.-**

គ.អ.ឆ.ក. មានរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមេសា ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com